**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ១០៧៣ **អយក.**ហវ

ថ្ងៃអង្គារ ៨កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក និងអគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពថ្នាក់កណ្តាល**
- **លោក លោកស្រី នាយក នាយិកាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិទ្យាល័យ**
- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
- **លោក លោកស្រី ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រី នាយក នាយិកាសាលារៀនសាធារណៈគ្រប់កម្រិត**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារពិនិត្យតាមដាន និងវាយតម្លៃ។

**យោង ៖** ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦ របស់នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រកាស ដាក់ឱ្យអនុវត្តចាប់តាំងពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ដោយមានចក្ខុវិស័យ **"ប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ"**។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតក្នុងដំណាក់កាលទី៤ **"គណនេយ្យភាពសមិទ្ធកម្ម"** ដែលជាដំណាក់កាលយុទ្ធសាស្ត្រឈានឆ្ពោះទៅអនុវត្ត **"ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម"**។ ក្នុងនាមជាប្រតិបត្តិករ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃនៅគ្រប់កម្រិត និងឱ្យបានទូលំទូលាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាឧបករណ៍កំណត់ចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពនៃរាល់ការអនុវត្តផែនការសកម្មភាព។ ទន្ទឹមនេះ ក្រសួងបានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារពិនិត្យតាមដាន និងវាយតម្លៃក្នុងគោលបំណងចូលរួមចំណែកគាំទ្រដល់ការពិនិត្យតាមដាន និងវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុឱ្យ



អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

កាន់តែមានតម្លាភាព និងគណនេយ្យភាពសម្រាប់ធ្វើសេចក្ដីសម្រេចចិត្ត ដោយឈរលើមូលដ្ឋានត្រឹមត្រូវ និងច្បាស់លាស់ព្រមទាំងស្របជាមួយនឹងបរិបទនៃសង្គមឌីជីថល។ ក្នុងន័យនេះ ក្រសួងសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **"ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារពិនិត្យតាមដាន និងវាយតម្លៃ"** ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការពង្រឹងប្រសិទ្ធភាពលើការពិនិត្យតាមដាន និងវាយតម្លៃឱ្យប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
- -អគ្គលេខាធិការដ្ឋាន
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- -កាលប្បវត្តិ
- -ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ